00629433

លេខ/No: D427/4/11

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១០៥)

ភាគីដាក់ឯកសារ: សហមេធាវីការពារក្តីលោក ខៀវ សំផន

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ អ.ប.ជ: សាធារណៈ / Public

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 01 / 12 / 2010
ម៉ោង (Time/Heure): 14 : 20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

---

## សំណើសុំជាបន្ទាន់ឲ្យធ្វើការបំភ្លឺលើនីតិវិធី

---

| <u>ដាក់ដោយ</u>៖ | <u>ផ្ញើជូន</u>៖ |
|---|---|
| **សហមេធាវីការពារក្តីលោក ខៀវ សំផន** | **អង្គបុរេជំនុំជម្រះ** |
| លោក ស សូវាន | ចៅក្រម ប្រាក់ គឹមសាន |
| លោក Jacques VERGES | ចៅក្រម ន័យ ធុល |
| លោក Philippe GRECIANO | ចៅក្រម ហួត វុទ្ធី |
| **ជំនួយការ៖** | ចៅក្រម Catherine MARCHI-UHEL |
| លោកស្រី សេង សុជាតា | ចៅក្រម Rowan DOWNING |
| កញ្ញា Clémence WITT | **សហព្រះរាជអាជ្ញា៖** |
| | លោកស្រី ជា លាង |

00629434

លេខ/No: D427/4/11

០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស-អ.ប.ជ ១០៤

លោក Andrew CAYLEY

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីគ្មានតំណាង**

លេខ/No: D427/4/11

០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស-អ.ប.ជ ១០៤

# សូមគោរពអង្គបុរេជំនុំជម្រះ

1. តាមរយៈបណ្តឹងនេះ សហមេធាវីការពារក្តីរបស់លោក ខៀវ សំផន សូមអង្គបុរេជំនុំជម្រះមេត្តាធ្វើការបំភ្លឺលើនីតិវិធីទាក់ទងនឹងសិទ្ធិឆ្លើយតបរបស់ពួកគាត់ ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាលើបណ្តឹងឧទ្ធរណ៍លោក ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ (“**ចម្លើយ**”)[1] ហើយដែលចម្លើយនេះត្រូវបានជូនដំណឹងមកក្រុមមេធាវីការពារក្តីជាភាសាបារាំង កាលពីថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០១០នេះ។

2. តាមពិត នៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនេះ សហមេធាវីការពារក្តីលោក ខៀវ សំផន បានសុំឱ្យបើកសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈនៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយអនុលោមតាមវិធាន ៧៧ ៣) និង៧៧ ៦) នៃវិធានផ្ទៃក្នុង។[2]

3. តាមបញ្ញត្តិ នៃមាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅអ.វ.ត.ក “*សំណើឆ្លើយតបចំពោះសារណាតបនឹង<u>ត្រូវអនុញ្ញាត តែក្នុងករណីដែលមិនមានការស្នើសុំឱ្យមានការដេញដោលដោយផ្ទាល់មាត់</u> ហើយការឆ្លើយតបនោះត្រូវដាក់ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃនៃប្រតិទិន គិតពីថ្ងៃជូនដំណឹងជាភាសាដែលភាគីបានស្នើសុំ ដែលបានចែងក្នុងមាត្រា ២-២ អំពីឯកសារដែលអ្នកទាំងនោះត្រូវឆ្លើយតប។*”

4. នៅពេលជូនដំណឹងអំពីចម្លើយរួមរបស់សហព្រះរាជអាជ្ញា លើបណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តីទាំងបីក្រុមផ្សេងទៀត[3] អង្គបុរេជំនុំជម្រះបានចេញសេចក្តីណែនាំឱ្យពួកគេឆ្លើយតប

---

[1] ចម្លើយរបស់សហព្រះរាជអាជ្ញា តបនឹងសារណាបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី២៩ វិច្ឆិកា ២០១០ *ឯកសារតុលាការ D427/4/7*។

[2] សារណាបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី១៨ តុលា ២០១០ *ឯកសារតុលាការ D427/4/3 កថាខណ្ឌ៥៨ ដល់ ៦០*។

ជាលាយល័ក្ខណ៍អក្សរ ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញា[4] ក្នុងរយៈពេលដប់ថ្ងៃ (ទៅតាមសំណើសុំរបស់ក្រុមការពារក្ដីលោកស្រី អៀង ធិរិទ្ធ និងលោក អៀង សារី)[5]។

5. ផ្ទុយស្រឡះពីជនជាប់ចោទដទៃទៀត លោក ខៀវ សំផន មិនបានទទួលការជូនដំណឹងណាមួយពីអង្គបុរេជំនុំជម្រះទាក់ទងនឹងការបើកសវនាការដេញដោល និងសិទ្ធិរបស់គាត់ក្នុងការឆ្លើយតបជាលាយល័ក្ខណ៍អក្សរនោះឡើយ។

6. អាស្រ័យហេតុនេះ សហមេធាវីការពារក្ដីលោក ខៀវ សំផន សូមអង្គបុរេជំនុំជម្រះមេត្តា បំភ្លឺលើនីតិវិធី ដើម្បីដោះស្រាយភាពខ្វះចន្លោះនេះ និងអនុញ្ញាតឱ្យលោក ខៀវ សំផន អាចទទួលបាននូវសិទ្ធិរបស់គាត់ក្នុងលក្ខខណ្ឌដូចគ្នានឹងជនជាប់ចោទដទៃទៀតផងដែរ។

7. ទោះក្នុងករណីណាក៏ដោយ ប្រសិនបើចៅក្រមអង្គបុរេជំនុំជម្រះ សម្រេចមិនអនុញ្ញាតទៅតាមសំណើសុំឱ្យបើកសវនាការជាសាធារណៈរបស់ខ្លួនទេនោះ សហមេធាវីការពារក្ដីរបស់លោក ខៀវ សំផន សូមឱ្យគិតថិរវេលាសម្រាប់ធ្វើការឆ្លើយតបចាប់ពីថ្ងៃបន្ទាប់ បន្ទាប់ពីបានទទួលសេចក្ដីជូនដំណឹងអំពីសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបញ្ហានេះ ស្របតាមវិធានដែលកំពុងអនុវត្តនាពេលនេះ[6]។ លើសពីនេះទៀត ដោយពិចារណាលើកាលៈទេសៈជាក់ស្ដែង មេធាវី

---

[3] សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាអាជ្ញា ស្នើសុំដាក់ចម្លើយរួមលើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី ខៀវ សំផន និងអៀង ធិរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ និងសំណើសុំបន្ថែមចំនួនទំព័រកំណត់ ថ្ងៃទី២៨ តុលា២០១០ *ឯកសារតុលាការ D427/4/*4។

[4] សេចក្ដីជូនដំណឹងថ្ងៃទី២៤ វិច្ឆិកា ២០១០ ស្ដីពី៖ "ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍ នួន ជា អៀង សារី និងអៀង ធីរិទ្ធ" (ឯកសារភ្ជាប់មកជាឧបសម្ព័ន្ធ)។

[5] សំណើរបស់មេធាវីការពារ អៀង ធីរិទ្ធ សុំពន្យារពេលកំណត់ ដើម្បីឆ្លើយតបចំពោះចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ និងនួនជា ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី១៨ វិច្ឆិកា ២០១០ *ឯកសារតុលាការ D427/2/5*។ សំណើបន្ទាន់របស់លោក អៀង សារី សុំពន្យារពេលកំណត់ និងបន្ថែមចំនួនទំព័រកំណត់ដើម្បីឆ្លើយតបចំពោះចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ បើសិនជាគ្មានសវនាការដេញដោលដោយផ្ទាល់មាត់ថ្ងៃទី១៩ វិច្ឆិកា ២០១០ *ឯកសារតុលាការ D427/1/16*។

[6] សេចក្ដីបញ្ជាក់ស្ដីពីការគណនាថ្ងៃផុតកំណត់នៃការដាក់ឯកសារទាំងឡាយដែលត្រូវដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ ថ្ងៃទី២២ កញ្ញា ២០១០ សំណុំរឿងលេខ 00២/១៩-0៩-២00៧-អវតក-កសចស (អបជ)។

លេខ/No: D427/4/11

០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស-អ.ប.ជ ១០៤

ការពារក្តីលោក ខៀវ សំផន សូមអង្គបុរេជំនុំជម្រះមេត្តាអនុញ្ញាតឱ្យពេលបន្ថែមចំនួនប្រាំថ្ងៃទៀត សម្រាប់ធ្វើការឆ្លើយតប ប្រសិនបើយល់ថាចាំបាច់។

**រក្សាសិទ្ធិកែប្រែគ្រប់បែបយ៉ាង**
**និងដើម្បីយុត្តិធម៌**

| | | | |
|---|---|---|---|
| | មេធាវី **ស សុវាន**<br>មេធាវី **Jacques VERGÈS**<br>មេធាវី **Philippe GRECIANO** | ភ្នំពេញ<br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |